## ៣.១១ ការពង្រឹងប្រព័ន្ធពិនិត្យតាមដានរបស់កម្មវិធី

### វត្ថុបំណង និង យុត្តិកម្ម

វត្ថុបំណងរបស់កម្មវិធីគឺ ពង្រឹងការពិនិត្យតាមដានផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស នៅគ្រប់កំរិតទាំងអស់ ដើម្បីកែលំអគោលនយោបាយ យុទ្ធសាស្ត្រ និងការអភិវឌ្ឍកម្មវិធី ការអនុវត្តការងារ និង ការគ្រប់គ្រងនៅក្នុងដំណើរការកែទម្រង់របស់វិស័យទាំងមូល ។ ការពិនិត្យតាមដានដែលតម្រង់ទៅរកលទ្ធផលការងារទាន់ពេលវេលា និង មានប្រសិទ្ធភាព ការវាយតម្លៃ និង ការស្រាវជ្រាវ ការកសាងដោយផ្អែកលើសមិទ្ធិផល និងបទពិសោធន៍ដែលទទួលបានគឺជាប្រការសំខាន់សំរាប់លើកកំពស់ប្រសិទ្ធភាព និង ការបំពេញការងារ ។ នៅក្នុងលក្ខណៈនេះវត្ថុបំណងជាអាទិភាពគឺ ពង្រឹងសមត្ថភាពផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ ការងារគណនេយ្យ និង សវនកម្ម នៅក្នុងបរិបទនៃរបៀបវារៈកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ។ វត្ថុបំណងជាគន្លឹះមួយទៀតគឺ ពង្រឹងការពិនិត្យតាមដាន វាយតម្លៃការបំពេញការងារវិស័យអប់រំប្រកបដោយតម្លាភាព គណនេយ្យភាពនៅក្នុងសកម្មភាពអប់រំលើគ្រប់ទិដ្ឋភាព តាមរយៈការពង្រឹងការអនុវត្តការប្រើប្រាស់ស្តង់ដាគុណភាព និង ប្រសិទ្ធភាពអប់រំគ្រប់ផ្នែក និងការចូលរួមពីអ្នកពាក់ព័ន្ធ នៅក្នុងដំណើរការកែទម្រង់វិស័យអប់រំ ។

### វិសាលភាព និង ភាពគ្របដណ្តប់

កម្មវិធីនេះផ្តោតលើការកសាងសមត្ថភាព ដើម្បីលើកកំពស់ការងារប្រមូលទិន្នន័យ ការវិភាគ និង ការពិនិត្យតាមដានរបស់អង្គភាពគ្រប់គ្រងថវិកា BMC នៅរដ្ឋបាលកណ្តាលដែលនៅក្នុងនោះមាន : នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានផែនការ លេខាធិការដ្ឋានសវនកម្មផ្ទៃក្នុង និងអធិការដ្ឋានអប់រំ ព្រមទាំងអង្គភាពគ្រប់គ្រងថវិកាទាំង២៤ខេត្ត-ក្រុង ១៨៤ស្រុក-ខ័ណ្ឌ និង ការិយាល័យអប់រំស្រុក-ខ័ណ្ឌចំនួន៨១ ។ កម្មវិធីនេះ នឹងពង្រឹងក្រុមការងារពិនិត្យតាមដានថ្នាក់ខេត្ត-ក្រុង និង ថ្នាក់ស្រុក-ខ័ណ្ឌបន្ថែមទៀត ដោយផ្ទេរការទទួលខុសត្រូវទៅឱ្យកម្មវិធីសកម្មភាពជាអាទិភាពនីមួយៗ ឬ ជាក្រុម ។ បញ្ហាសំខាន់នៃការងារនេះគឺត្រូវចុះពិនិត្យជាប្រចាំនៅតាមអង្គភាពគ្រប់គ្រងថវិកា និង គ្រឹះស្ថានសិក្សាសាលារៀន ស្របតាមចំណុចដៅដែលបានឯកភាព និងការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និង បច្ចេកទេសទាន់ពេលវេលារបស់មន្ទីរអប់រំ យុវជន និង កីឡាខេត្ត-ក្រុងជូនទៅរដ្ឋបាលកណ្តាល ស្របទៅតាមកាលវិភាគប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆ្នាំ។ កម្មវិធិនេះនឹងជួយគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធបន្ថែមទៀត ដែលរួមមានសេចក្តីណែនាំស្តីពីការពិនិត្យតាមដាន និង ធ្វើរបាយការណ៍នៅកំរិតផ្សេងៗរបស់ប្រព័ន្ធអប់រំ ។

បញ្ហាអាទិភាពជាគន្លឹះគឺ លើកកំពស់វិសាលភាព និងគុណភាពអ្នកជាប់ពាក់ព័ន្ធ និងដៃគូពាក់ព័ន្ធនានា នៅក្នុងការពិនិត្យតាមដាន ដើម្បីកែលំអគណនេយ្យភាព និងតម្លាភាព។ ប្រការនេះរួមមាន ការពង្រឹងបន្ថែមទៀតនូវដំណើរការពិនិត្យឡើងវិញប្រចាំឆ្នាំរួមគ្នារវាង ក្រសួងអប់រំ យុវជន និង កីឡា អង្គការក្រៅរដ្ឋាភិបាល អ្នកផ្តល់

ជំនួយ និងអ្នកពាក់ព័ន្ធដទៃទៀតលើការបំពេញការងារប្រចាំឆ្នាំ ពង្រឹងតួនាទីគណៈកម្មាធិការ និងលេខាធិការដ្ឋានអប់រំសំរាប់ទាំងអស់គ្នា និងការប្រើប្រាស់ប្រព័ន្ធសវនកម្មខាងក្រៅតាមរយៈអាជ្ញាធរជាតិសវនកម្ម។

**សង្ខេបសកម្មភាពសំខាន់ៗ**

១. *ពង្រឹងការពិនិត្យតាមដានហិរញ្ញវត្ថុ* ៖ សកម្មភាពគន្លឹះរួមមាន ក) ពង្រឹងសមត្ថភាពនាយកដ្ឋានហិរញ្ញវត្ថុលើការពិនិត្យតាមដាន និង ការធ្វើរបាយការណ៍អំពីការបញ្ចេញ និង លំហូរថវិការបស់កម្មវិធីសកម្មភាពជាអាទិភាពនានា តាមរយៈរតនាគារជាតិខេត្ត-ក្រុង អង្គភាពគ្រប់គ្រងថវិកា និងគ្រឹះស្ថានសិក្សា សាលារៀន។ ខ) ពង្រឹងប្រព័ន្ធសន្តិសុខហិរញ្ញវត្ថុនៅគ្រប់កំរិតរបស់ប្រព័ន្ធ ជាពិសេសនៅថ្នាក់ខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌ ដែលរួមមានការប្រើប្រាស់ប្រព័ន្ធធនាគារខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ គ) ពង្រឹងសមត្ថភាពមន្ទីរអប់រំ យុវជន និង កីឡាខេត្ត-ក្រុង និង ការិយាល័យអប់រំ យុវជន និងកីឡាស្រុក-ខ័ណ្ឌ ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេសជាប្រចាំដល់អង្គភាពគ្រប់គ្រងថវិកា និងសាលារៀន ដើម្បីធានាសកម្មភាពទាន់ពេលវេលាលើការចំណាយ និង ការធ្វើរបាយការណ៍។ ឃ) បំប៉នបុគ្គលិកពីការអភិវឌ្ឍប្រព័ន្ធគណនេយ្យ ដែលរួមមានភាពសមស្របទៅនឹងបទដ្ឋានថ្មីដែលបានកើតចេញពីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

២. *ពង្រឹងការពិនិត្យតាមដានផលប៉ះពាល់* ៖ សកម្មភាពគន្លឹះរួមមាន ក) អភិវឌ្ឍយុទ្ធសាស្ត្រ និងអាទិភាពសំរាប់ការងារស្រាវជ្រាវជាក់ស្តែង។ ខ) ពង្រឹងសមត្ថភាពមន្ទីរអប់រំ យុវជន និង កីឡាខេត្ត-ក្រុង និងការិយាល័យអប់រំ យុវជន និង កីឡាស្រុក-ខ័ណ្ឌ ក្នុងការអនុវត្តការប្រមូល និងវិភាគទិន្នន័យ ការពិនិត្យតាមដានការរីកចំរើន និងការធ្វើរបាយការណ៍ស្តីពីការងារសកម្មភាពជាអាទិភាព។ គ) អភិវឌ្ឍន៍នៅថ្នាក់ស្រុក-ខ័ណ្ឌនូវកម្មវិធី និង យុទ្ធសាស្ត្រនានានៃការពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ និងសហគមន៍។

៣. *ពង្រឹងសវនកម្មផ្ទៃក្នុង* ៖ សកម្មភាពគន្លឹះរួមមាន ក) ពង្រីក និង ពង្រឹងសកម្មភាពសវនកម្ម នៅរដ្ឋបាលកណ្តាល និងថ្នាក់ខេត្ត-ក្រុង តាមរយៈ កម្មវិធីអភិវឌ្ឍន៍ជំនាញ និការបំប៉នពេញលេញមួយ។ ខ) បញ្ចប់ការរៀបចំសេចក្តីណែនាំស្តីពីការធ្វើសវនកម្មផ្ទៃក្នុង និង ឯកសារសវនកម្ម គ) ពង្រឹងគណៈកម្មការសវនកម្មផ្ទៃក្នុងរបស់ក្រសួងអប់រំ យុវជន និង កីឡា។

៤- *ពង្រឹងសវនកម្ម និងការពិនិត្យតាមដានគុណភាព និង ស្តង់ដា* ៖ សកម្មភាពគន្លឹះរួមមាន ក) គំរូតាងការពិនិត្យតាមដានចំពោះការបំពេញការងារទូទៅរបស់សាលារៀន ខ) គំរូតាងការវាយតម្លៃចំពោះការបំពេញការងាររបស់អ្នកគ្រប់គ្រងនិងគ្រូបង្រៀន គ) គំរូតាងការពិនិត្យឡើងវិញចំពោះសកម្មភាព

បង្រៀន និង រៀន។ ក្រសួងអប់រំ យុវជន និង កីឡា នឹងរៀបចំក្របខ័ណ្ឌការងារសមស្របមួយ ដែលរួមមានការកំណត់អាំងឌីកាទ័រគុណភាព និង វិធានការសំរាប់ផ្ទៀងផ្ទាត់។

## ការគ្រប់គ្រង និង ការពិនិត្យតាមដានកម្មវិធី

អង្គភាពគ្រប់គ្រងថវិការបស់នាយកដ្ឋានហិរញ្ញវត្ថុ ទទួលខុសត្រូវលើការពិនិត្យតាមដានផ្នែកហិរញ្ញវត្ថុ។ ប្រធាននាយកដ្ឋានដែលជាប្រធានអង្គភាពគ្រប់គ្រងថវិកា ទទួលខុសត្រូវលើការធ្វើផែនការ និងការអនុវត្តការងារពិនិត្យតាមដាន និងសំរបសំរួល ក្នុងការងារគ្រប់គ្រងហិរញ្ញវត្ថុ។

អង្គភាពគ្រប់គ្រងថវិការបស់នាយកដ្ឋានផែនការទទួលខុសត្រូវលើការពិនិត្យតាមដានផលប៉ះពាល់ ដែលរួមមានការពិនិត្យតាមដានផ្នែកបច្ចេកទេស ការវាយតម្លៃ និង ការសិក្សាស្រាវជ្រាវប្រតិបត្តិ។ ការទទួលខុសត្រូវដ៏ទូលំទូលាយរបស់ក្រុមពិនិត្យតាមដាននៅថ្នាក់ខេត្ត-ក្រុង ដឹកនាំដោយប្រធានមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង និងត្រូវធានាថាផែនការការងារ និង របាយការណ៍ពិនិត្យតាមដាន ស្របគ្នាជាមួយនឹងសេចក្ដីណែនាំ និងចំណុចដៅដែលបានឯកភាព និងត្រូវបានបញ្ជូនដោយអនុលោមតាមកាលវិភាគដែលបានព្រមព្រៀង គ្នា។ មូលនិធិត្រូវបានផ្ទេរទៅឱ្យអង្គភាពគ្រប់គ្រងថវិកាខេត្ត-ក្រុង សំរាប់ធ្វើសកម្មភាពពិនិត្យតាមដាន។

ក្រសួងអប់រំ យុវជន និង កីឡា នឹងបែងចែកមូលនិធិសំរាប់ដំណើរការសវនកម្មផ្ទៃក្នុង តាមរយៈ BMC អគ្គាធិការដ្ឋាន។ ការធ្វើរបាយការណ៍សវនកម្ម នឹងត្រូវបង្ហាញជូនគណៈកម្មការសវនកម្មក្រសួងអប់រំ យុវជន និង កីឡា ដែលជាមូលដ្ឋានមួយសំរាប់ធ្វើសកម្មភាពសមស្រប។ អធិការដ្ឋានអប់រំ នឹងក្លាយទៅជាអង្គភាពគ្រប់គ្រងថវិកា ដើម្បីទទួលខុសត្រូវការពិនិត្យតាមដានគុណភាពអប់រំ។

## ផែនការហិរញ្ញវត្ថុ

ផែនការហិរញ្ញវត្ថុបានផ្ដល់អាទិភាពចំពោះការពង្រីក និង ការពង្រឹងការងារសវនកម្ម និង ការពិនិត្យតាមដានផ្នែកហិរញ្ញវត្ថុ។ ការបែងចែកថវិកាដោយឡែកៗត្រូវបានរៀបចំសំរាប់ថ្នាក់ខេត្ត-ក្រុង និង ស្រុក-ខ័ណ្ឌ ដោយពិចារណាទៅលើចំនួនស្រុក-ខ័ណ្ឌ សាលារៀន និងអង្គភាពគ្រប់គ្រងថវិកា ដែលមាននៅក្នុងខេត្ត-ក្រុង នីមួយៗ។ ផែនការហិរញ្ញវត្ថុនេះ ក៏គ្របដណ្ដប់លើវិសាលភាពនៃការពិនិត្យតាមដានគុណភាពអប់រំផងដែរ។

*តារាង ១២: ផែនការហិរញ្ញវត្ថុសំរាប់ការពង្រឹងប្រព័ន្ធពិនិត្យតាមដានរបស់កម្មវិធី*

| សកម្មភាព | ចំណាយគិតជា លានរៀល | | | | |
|---|---|---|---|---|---|
| | 2004 | 2005 | 2006 | 2007 | 2008 |
| ១-ពង្រឹងការពិនិត្យតាមដានផ្នែកហិរញ្ញវត្ថុ | 5,400 | 3,000 | 1,600 | 1,600 | 2,100 |
| ២-ពង្រឹងការពិនិត្យតាមដានផលប៉ះពាល់ | 300 | 300 | 300 | 300 | 300 |
| ៣-ពង្រឹងសវនកម្មផ្ទៃក្នុង និងអធិការកិច្ច | 1,600 | 1,300 | 800 | 800 | 1,200 |
| ៤-ពង្រឹងការពិនិត្យតាមដានគុណភាព | 400 | 500 | 500 | 500 | 500 |
| **ធនធាន :សរុប** | **7,700** | **5,100** | **3,200** | **3,200** | **4,100** |